## ខ្លឹមសារសង្ខេប

### សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល លើសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរក្នុងគោលបំណងដើម្បីវាយតម្លៃលើភាពអាចជឿជាក់បានរបស់ សំ សិទ្ធី (F28/4)

១.ផ្នែកមួយនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង(Trial Chamber of the ECCC) https://www.eccc.gov.kh/km/document/court/saalkrmsmnnumryang-00201 ក្នុងសំណុំរឿង ០០២/១ យោងដល់សក្ខីកម្មរបស់ សាក្សី សំ សិទ្ធី ដែលគូសបញ្ជាក់នូវគោលនយោបាយសម្លាប់ទាហានរប បលន់ណុល ដែលពាក់ព័ន្ធជាមួយនឹងជនជាប់ចោទ នួន ជា (NC)។ នួន ជា បានពិចារណាថា សក្ខីកម្មមិនមានសង្គតិភាព និងខ្វះអ្វីផ្សេងមានគាំទ្រ (corroboration)។ មូលហេតុនេះហើយ ក្នុងដំណើរការពិនិត្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់ TC លោក នួន ជា បានដាក់សំណើមកអង្គជំនុំជម្រះតុលាការកំពូល (Supreme Court Chamber:SCC) ដើម្បីវាយតម្លៃភាពជឿជាក់នៃសក្ខីកម្មរបស់សាក្សីរូបនេះhttp://www.measboralaws.com/detail/1061។ សហព្រះរាជអាជ្ញា (CoProsecutor: CoP) http://www.measboralaws.com/detail/1063 និងដើមបណ្តឹងរដ្ឋប្បវេណី(Civil Party: CP) បាន ដាក់ចម្លើយ និង សារណាឆ្លើយតបរៀងៗខ្លួន http://www.measboralaws.com/detail/1062 ។

២. CoP និង CP បានឆ្លើយតបថា NC ហាក់ដូចជាឲ្យតម្លៃលើសាក្សីរូបនេះជាសំខាន់។ តាមពិតព័ត៌មាន ដែលគាត់ផ្តល់ជូននេះ ជាប្រភេទទូទៅដែលគេដឹងលឺ។ សំណើនេះ នាំឲ្យមានការពន្យាដំណើរការពិចារណាឈានទៅចេញសាលដីកា។ CoP អះអាងបន្ថែមអំពីកង្វះខាតនៃការយកចិត្តទុកដាក់ការងារនៃក្រុមការពារលោក NC ហើយសំណើនេះ ពិតជាមិនចាំបាច់យ៉ាងពិតប្រាកដ (កថាខ័ណ្ឌទី ៤ និង៥)។ NC បានឆ្លើយតបថា ភាគី CoP បានបកស្រាយខុសនូវគំហើញរបស់ TC និងមូលហេតុនៃការដាក់សំណើ ព្រមទាំង បានអះអាងថា CoP ប្រើប្រាស់ពាក្យមិនគួរគប្បីមកលើខ្លួន (កថាទី ៦)។

៣. SCC បានគាំទ្រផ្នែកខ្លះ លើកឡើងរបស់មេធាវី ព្រមទាំងរំលឹកនូវវោហាស័ព្ទមិនសមសួនរបស់ CoP មុននឹងផ្តល់សំអាងហេតុ និងសម្រេច។ SCC បានលើកឡើងថា ជាការអនុវត្ត សាក្សីត្រូវបានផ្តល់សក្ខីកម្មជាសាធារណៈក្នុងតុលាការ ហើយត្រូវបានពិចារណាឆ្លុះនឹងកត្តា ឬព័ត៌មានដទៃទៀត។ នីតិវិធីនេះ ធ្វើឲ្យគំហើញ មានភាពជឿជាក់បាន ដោយមិនចាំបាច់ធ្វើការស៊ើបអង្កេតបន្ថែម។ វិធានការសមស្រប នឹងត្រូវបានលើកឡើងនៅពេលសវនាការនាពេលខាងមុខ។ ក្នុងពេលនោះ អង្គជំនុំជម្រះនេះនឹងអាចទាញសន្និដ្ឋានទាំងអស់ ដើម្បីវាយតម្លៃជាក់ស្តែងនូវភាពជឿជាក់បាននូវសក្ខីកម្មរបស់សាក្សីរូបនេះ៖ *នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ វាពុំមានលក្ខណៈចាំបាច់ដែលតម្រូវឲ្យបើកកិច្ចស៊ើបសួរបន្ថែម ពី*

*ព្រោះអង្គជំនុំជម្រះនេះ បានធ្វើសេចក្តីសន្និដ្ឋានបានហើយលើចំណុច ដែលខ្លួនយល់ថា ចាំបាច់ក្នុងការវាយតម្លៃពីសក្ខីកម្មផ្ទាល់របស់សាក្សីរូបនេះ* (កថាខ័ណ្ឌទី ១៣)។ SCC សម្រេចបដិសេធនូវសំណើនេះ។

<u>**កំណត់សំគាល់៖**</u> <u>១.</u> សវនាការនៅតុលាការជាន់ខ្ពស់លើកទី១ ផ្តោតជាសំខាន់លើ អង្គច្បាប់ (ច្បាប់អនុវត្ត ឬការបកស្រាយ)។ ការពិចារណាសាទុក្ខលើកទី២ នឹងផ្តោតលើទាំងអង្គហេតុ និងច្បាប់។ ទោះបីជាយ៉ាងនេះក្តី ការពិចារណាអង្គហេតុ ឬដាក់ភស្តុតាងថ្មី ជាករណីលើកលែងតែប៉ុណ្ណោះ ដោយសារតុលាការជាន់ខ្ពស់ យល់ថាអង្គហេតុទាំងនោះត្រូវបានពិនិត្យរួចហើយ។ តុលាការជាន់ខ្ពស់ផ្តល់តម្លៃឬគោរព (deference) នូវគំហើញ របស់តុលាការអង្គហេតុ (first instance)។ SCC ទំនងជា ពិចារណាដល់សិទ្ធិទទួលបាននូវការសម្រេចសេចក្តីក្នុងពេលសមស្រប។ ការណ៍ទទួលសំណើ និងបើកការស៊ើបអង្កេតបន្ថែម អាចនាំឲ្យពន្យានីតិវិធី និងអាចពន្យាពេលយូរជាយថាហេតុ ដោយសារ ការទុកនូវរយៈពេលដល់ភាគីក្នុងការឆ្លើយតប តាមគោលការណ៍សមភាពនៃភាគី (equality of arms) http://www.measboralaws.com/detail/1065 បន្ទាប់ពីទទួលយកសំណើនេះមកពិនិត្យ។ <u>២.</u> មាត្រាដែលពាក់ព័ន្ធ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ នៃកម្ពុជា មិនបានចែងឲ្យពិចារណានូវសំណើភាគីវាយតម្លៃនូវភាពជឿជាក់នៃសក្ខីកម្មរបស់សាក្សី។ ទោះបីជាយ៉ាងនេះក្តី តុលាការកំពូលអាចប្រើឆន្ទានុសិទ្ធិទទួលសំណើ ឬមិនទទួល ហើយការអនុញ្ញាតឲ្យមានការស៊ើបសួរបន្ថែមទៀត ក៏ទំនងជារឹតត្បិតខ្លាំង (សូមមើលមាត្រា ៤៣៤)។